# ក្រុមហ៊ុនលូសេនថេកស្ទាយ(ខេមបូឌា)ខូ.,អិលធីឌី

**LOUSEN TEXTILE(CAMBODIA)Co.,LTD**

## កិច្ចព្រមព្រៀង

នៅថ្ងៃសុក្រ០១កើតខែជេស្ឋឆ្នាំជូតទោស័គព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២២ខែមេសាឆ្នាំ២០២០នៅវេលាម៉ោង០៣.០០នាទីព្រឹក**ក្រុមហ៊ុន លូ សេន ថេកស្ទាយ(ខេមបូឌា)ខូ.,អិលធីឌី** ដែលមានអាស័យដ្ឋានភូមិ បឹងធំទី១ សង្កាត់ បឹងធំ ខណ្ឌកំបូលរាជធានីភ្នំពេញបានរៀបចំការប្រជុំជាមួយថ្នាក់ដឹកនាំ ក្នុងរោងចក្រជាមួយសហជីពមូលដ្ឋានប្រចាំក្រុមហ៊ុនដែលមានខ្លឹមសារដូចខាងក្រោម៖

**១-ភាគីនិយោជករួមមាន:**

- ១-លោក YANG CHIN LIANG នាយកក្រុមហ៊ុន
- ២-កញ្ញា CHAN SOCHEATA ប្រធានរដ្ឋបាល
- ៣-លោក ZHU SHI HUA ប្រធានរោងចក្រ
- ៤-លោកស្រី UM NAVY ជំនួយការរដ្ឋបាល និងជាលេខាកត់ត្រា

**២-ភាគីសហជីព រួមមាន:**

- ១-លោក សែម ស៊ុនលី ប្រធានសហជីពប្រចាំមូលដ្ឋបាល
- ២-អ្នកស្រីម៉ុក សាមុត ជាអនុប្រធានសហជីព
- ៣-លោក យ៉ន ពៅ លេខធិការសហជីព

**៣-អង្គន័យនៃអង្គប្រជុំមានដូចខាងក្រោម:**

៣.១.ភាគីទាំងពីរបានឯកភាពគ្នាទៅតាមកាស្នើសុំរបស់ក្រុមហ៊ុនព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៣៧នាក់រយៈពេល០១ខែដោយគិតចាប់ពីថ្ងៃទី០១ខែមិថុនាឆ្នាំ២០២០រហូតដល់ ថ្ងៃទី៣០ខែមិថុនាឆ្នាំ២០២០ ។ ដោយយោងទៅលើមូលហេតុខាងភ្ញៀវមិនមានចំនួនកុម៉្មង់អោយខាងក្រុមហ៊ុនយើងខ្ញុំធ្វើ ទើបខាងក្រុមហ៊ុនមិនមានការងារផ្តល់ជូនកម្មករនិយោជិតធ្វើរហូតដល់មានការជូនដំណឹងភ្ញៀវបញ្ជាទិញសារជាថ្មី ។

៣.៣.ភាគីក្រុមហ៊ុនឯកភាពបើកប្រាក់ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតសម្រាប់ខែក្នុងខែមិថុនាបើកនៅថ្ងៃទី១០ខែកក្កដាឆ្នាំ២០២០រៀងរាល់ម៉ោង៣.៣០នាទីរសៀល ។

៣.២.ភាគីទាំងពីរក៏បានឯកភាពគ្នាព្រមទទួលយកការផ្តល់ប្រាក់ឈ្នួលក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារអនុវត្តន៍តាមប្រកាសលេខ០៤៥/២០ក.ប./ស.ណ.ន.ខ.លចុះថ្ងៃទី១៧ខែមេសាឆ្នាំ២០២០ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈអនុវត្តន៍ដូចខាងក្រោមនេះ៖

រោងចក្រត្រូវផ្តល់ប្រាក់ឧបត្ថមចំនួន៣០ដុល្លារអាមេរិកសម្រាប់កម្មករនិយោជិតម្នាក់ៗ១ខែ ក្នុងនោះ៖

-ចំនួន១០ដុល្លារអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ០៧ថ្ងៃដល់១០ថ្ងៃ

-ចំនួន២០ដុល្លារអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃដល់២០ថ្ងៃ

-ចំនួន៣០ដុល្លារអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃដល់៣០ថ្ងៃ

ចំពោះកម្មករនិយោជិតត្រូវផ្តល់លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងលេខទូរសព្ទផ្ទាល់ខ្លួនដែលអាចទាក់ទងបាន មកផ្នែករដ្ឋបាលរោងចក្រដើម្បីចងក្រងជាបញ្ជីឈ្មោះផ្តល់ជូនទៅក្រសួងយកទៅរៀបចំនិតិវិធីបើកប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាលដែលមានចំនួន៤០ដុល្លារអាមេរិក ក្នុង១ខែតាមរយៈធនាគាឯកទេសវីងទៅកម្មករនិយោជិត។ករណីកម្មករនិយោជិតណាផ្លាស់ប្តូរលេខទូរសព្ទក្រោយពេលដែលបានបញ្ជូនមកផ្នែករដ្ឋបាលខាងក្រុមហ៊ុនមិនទទួលខុសត្រូវឡើយ។

**កម្មករនិយោជិតបានទទួលប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាលតាមរយៈភ្នាក់ងារវីង ដូចខាងក្រោម៖**

-ចំនួន១៥ដុល្លារអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ០៧ថ្ងៃដល់១០ថ្ងៃ

-ចំនួន៣០ដុល្លារអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃដល់២០ថ្ងៃ

-ចំនួន៤០ដុល្លារអាមេរិកសម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃដល់៣០ថ្ងៃ

ក្រោយពេលព្យួរកិច្ចសន្យាការងារចំនួន១០ថ្ងៃកម្មករនិយោជិតនឹងទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីងដែលជម្រាបដំណឹងអំពីទឹកប្រាក់ដែលត្រូវទទួលបាន។

ក្រោយពេលទទួលបានសារជូនដំណឹងនេះតាមទូរសព្ទ សូមបងប្អូនយកអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងទូរសព្ទដែលបានទទួលសារនោះ ទៅភ្នាក់ងារឯកទេសវីងណាមួយដែលនៅជិតផ្ទះរបស់លោកអ្នកបំផុត ដើម្បីបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលនោះ។ ធនាគារឯកទេសវីងនិងបង្វិលថវិកានោះជូនរដ្ឋាភិបាលវិញប្រសិនជាបងប្អូនណាម្នាក់ខកខានទៅបើកប្រាក់ឧបត្ថម្ភនោះ ក្នុងរយៈពេល១០ថ្ងៃ ក្រោយពីធនាគារឯកទេសវីង បានផ្ញើសារតាមទូរសព្ទជូនបងប្អូន។

៣.៤.កម្មករនិយោជិតត្រូវត្រឡប់មកបំពេញការងារជាធម្មតាវិញនៅថ្ងៃទី០១ខែកក្កដាឆ្នាំ២០២០ជាកំហិត បើនិយោជិតណាអវត្តមានមិនបានមកធ្វើការងារតាមការបរិច្ឆេទខាងលើនោះទេក្រុមហ៊ុនមានកម្មករចាត់ទុកថាពួកគាត់បានបោះបង់ការងារចោល ក្រុមហ៊ុនមិនទូរទាត់ប្រាក់ឈ្នួលនិងប្រាក់អត្ថប្រយោជន៍ផ្សេងៗដែលបាននិងកំពុងអនុវត្តន៍អោយឡើយ ។

៣.៥.កិច្ចប្រជុំពិភាក្សាគ្រប់ចំនុចខាងលើទាំងអស់ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ។

៣.៦.កិច្ចប្រជុំនេះបានចប់សព្វគ្រប់នៅវេលាម៉ោង០៣.៤៥នាទីថ្ងៃខែឆ្នាំដដែល ។

ថ្ងៃសុក្រ០១កើតខែជេស្ឋឆ្នាំជូត.ទោស័ក.ព.ស២៥៦៤

ត្រូវនឹងថ្ងៃទី២២ខែឧសភាឆ្នាំ២០២០

**នាយកក្រុមហ៊ុន** **តំណាងសហជីព** **អ្នកកត់ត្រា**

KINGDOM OF CAMBODIA
TEXTILE (CAMBODIA) Co., Ltd.

សេមស៊ុនលី យ៉ន ពៅ ម៉ុកសាមុត

YANG CHIN LIANG